**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**'រ.ទ.ស.ភ'**

លេខ ០២៤ ស.វ.ណ.

ភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៧

## សេចក្តីជូនដំណឹង
## ស្តីពីការចូលរួមដេញថ្លៃលក់ឡាយឡុងនូវសម្ភារបាត់បង់គុណភាព

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់អាជីវករក្នុងស្រុកទាំងអស់ឲ្យបានជ្រាបថា ៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានបំណងនឹងដាក់ដេញថ្លៃលក់ឡាយឡុងនូវសម្ភារបាត់បង់គុណភាព ដោយវិធីដេញថ្លៃ៣លើកក្នុងពេលតែមួយ។

ពាក្យស្នើសុំចូលរួមដេញថ្លៃមានលក់នៅ អង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃជូនដំណឹងនេះ ពីម៉ោង ០៨:០០ព្រឹក ដល់ម៉ោង១៦:៣០ល្ងាច រៀងរាល់ថ្ងៃធ្វើការ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ក្នុងតម្លៃ ១២០,០០០រៀល(មួយច្បាប់) ។

កាលបរិច្ឆេទបង្ហាញសម្ភារ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង១៤:៣០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវសម្ភារគឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទដេញថ្លៃ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង១៤:៣០នាទី នៅបន្ទប់បណ្តុះបណ្តាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (អគារអាជីវកម្ម ជាន់ទី២)។

គ្រប់ពាក្យសុំចូលរួមដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់ធានាការដេញថ្លៃយ៉ាងតិច ១០ (ដប់)ភាគរយនៃតម្លៃកំណត់ឲ្យដេញ។ ប្រាក់កក់ធានាការដេញថ្លៃនេះអាចដកវិញបាន ក្នុងរយៈពេល២សប្តាហ៍ក្រោយពីចេញសេចក្តីសម្រេចឯកភាពពី **ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**។

សម្រាប់រាល់ព័ត៌មានលំអិត សូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មដូចមានអាសយដ្ឋានខាងលើ ឬ តាមទូរស័ព្ទលេខ ០១៧ ៨១១ ៩១១។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត ជា វិសុទ្ធ**

<u>ចម្លងជូន៖</u>
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ